**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**

GENERAL DEPARTMENT OF TAXATION

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ CATG2026000026 អពដ

ថ្ងៃអង្គារ ១៤ រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦

**ជម្រាបជូន**
**លោក លោកស្រីនាយកសហគ្រាស**
**ធី.ខេ ប៊ីហ្សនេស ខនសាល់ធីង ឯ.ក**
T.K BUSINESS CONSULTING CO., LTD.

**កម្មវត្ថុ** ៖ ករណីស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។
**យោង** ៖
- ប្រកាសលេខ ២៣០ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ
- លិខិតស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ របស់សហគ្រាស **ធី.ខេ ប៊ីហ្សនេស ខនសាល់ធីង ឯ.ក** ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស សូមជម្រាបជូនលោក លោកស្រីដែលជានាយកសហគ្រាស ឱ្យបានជ្រាបថា ការស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ របស់លោក លោកស្រីកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦ ត្រូវបានអគ្គនាយកដ្ឋានពន្ធដារ សម្រេចអនុញ្ញាតផ្តល់ជូន។

ការអនុញ្ញាតផ្តល់ជូននូវអាជ្ញាបណ្ណនេះ សហគ្រាសរបស់លោក លោកស្រីមានសិទ្ធិក្នុងការផ្តល់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារជូនដល់អ្នកជាប់ពន្ធដូចជា ការចុះបញ្ជីពន្ធដារ ការប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ និងសេវាកម្មពាក់ព័ន្ធនឹងពន្ធដារផ្សេងទៀតបាន។ សម្រាប់ការបំពេញនូវការផ្តល់សេវាកម្មពាក់ព័ន្ធនឹងពន្ធដាររបស់សហគ្រាសលោក លោកស្រីជូនដល់អ្នកជាប់ពន្ធត្រូវបានផ្សារភ្ជាប់ជាមួយសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

**១. សិទ្ធិ** (ជាភ្នាក់ងារសេវាកម្មពន្ធដារ)

បន្ថែមលើសិទ្ធិដែលមានចែងក្នុងមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារដែលមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរធ្វើជាតំណាងស្របច្បាប់ពីអ្នកជាប់ពន្ធ មានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ
- បំពេញបែបបទពន្ធដារ
- ដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធអាករទាំងឡាយ ដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ចុះហត្ថលេខាជំនួសអ្នកជាប់ពន្ធ
- បង្ហាញ និងផ្តល់ឯកសារ របាយការណ៍ ឬលិខិតយុត្តិការផ្សេងៗពាក់ព័ន្ធនឹងពន្ធដាររបស់អ្នកជាប់ពន្ធដល់រដ្ឋបាលសារពើពន្ធ
- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ
- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ



អគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

- ទទួលព័ត៌មានជាប្រចាំអំពីការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្មនៃច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើជាដៃគូសហប្រតិបត្តិការល្អជាមួយរដ្ឋបាលសារពើពន្ធ ក្នុងគោលបំណងដើម្បី៖
    - ក. ពង្រីកនិងពង្រឹងការផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធឱ្យទាន់ពេលវេលា និងអាចទុកចិត្តបាន ដើម្បីជានាឱ្យការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារបានល្អប្រសើរ
    - ខ. ទប់ស្កាត់សកម្មភាពគេចវេះពន្ធ
    - គ. ផ្តល់អនុសាសន៍សម្រាប់ជាធាតុចូលដើម្បីបំពេញបន្ថែម និងអភិវឌ្ឍច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទំនើបកម្ម។

**២. ភារកិច្ច**

- ប្រកាស និងបង់ពន្ធឱ្យបានត្រឹមត្រូវ ទាន់ពេលវេលាតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ផ្តល់សេវាផ្សេងៗដល់អ្នកជាប់ពន្ធទាក់ទិននឹងពន្ធដារ ប្រកបដោយវិជ្ជាជីវៈ និងសុចរិតភាព
- សម្របសម្រួលដើម្បីឱ្យអ្នកជាប់ពន្ធអនុវត្តកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- រួមចំណែកទប់ស្កាត់បទល្មើសកេងបន្លំប្រាក់ពន្ធ តាមរយៈការផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធអំពីសកម្មភាពគេចវេះពន្ធ
- ផ្តល់លិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីអតិថិជនរបស់ខ្លួន និងបង្ហាញអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ជូនមន្ត្រីពន្ធដារក្នុងពេលបំពេញភារកិច្ចជាតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ
- ទំនាក់ទំនង ឬធ្វើការជាមួយរដ្ឋបាលសារពើពន្ធប្រកបដោយភាពស្មោះត្រង់
- ផ្តល់ឯកសារ កំណត់ត្រា បញ្ជីគណនេយ្យ និងព័ត៌មានផ្សេងៗទៀតទាក់ទិននឹងសកម្មភាពអាជីវកម្មរបស់អតិថិជន តាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- មិនត្រូវបង្ហាញ និងផ្តល់ព័ត៌មានសម្ងាត់នានាទាក់ទិននឹងពន្ធដារ របស់អតិថិជនខ្លួនទៅតតិយជនដោយគ្មានការអនុញ្ញាតពីអតិថិជនខ្លួនឡើយ លើកលែងតែមន្ត្រីពន្ធដារ ក្នុងពេល និងក្នុងគោលដៅបំពេញភារកិច្ចជាផ្លូវការតាមបទប្បញ្ញត្តិស្តីពីពន្ធដារ
- ផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារនូវបញ្ជីឈ្មោះបុគ្គលិក ដែលផ្តល់សេវាកម្មពន្ធដាររៀងរាល់ចុងខែ
- បន្តបង្កើន និងធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញទាក់ទិនវិជ្ជាជីវៈរបស់ខ្លួន ដើម្បីធានាថាសេវាកម្ម ដែលត្រូវបានផ្តល់ឱ្យអតិថិជន ប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សហគ្រាសរបស់លោក លោកស្រីនឹងធ្វើការផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារ ជូនដល់អ្នកជាប់ពន្ធ ប្រកបដោយសីលធម៌វិជ្ជាជីវៈ និងអនុវត្តកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីនាយកសហគ្រាសជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោក លោកស្រីនាយកសហគ្រាស ទទួលនូវការរាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**<u>ចម្លងជូន៖</u>**
- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- សាខាពន្ធដារខេណ្ឌពមកករ
- ឯកសារ-កាលប្បវត្តិ

លោក លោកស្រីអាចទាញយកកម្មវិធីទូរសព្ទដៃត្រួតពិនិត្យ និងតាមដានឯកសារ GDT Check & Track នៅទីនេះ៖

App Store

Play Store

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ/№ CATG2026000026 អពដ



# អាជ្ញាបណ្ណភ្នាក់ងារ
# សេវាកម្មពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ សូមបញ្ជាក់ថា

**ធី.ខេ ប៊ីហ្សនេស ខនសាល់ធីង ឯ.ក**

អាសយដ្ឋាន៖ #អគារលេខ ១០ បន្ទប់ លេខ ១FB-E ផ្លូវ ១០៩ ក្រុមទី៤៨ ភូមិ ៧ សង្កាត់ មិត្តភាព ខណ្ឌ ៧មករា រាជធានីភ្នំពេញ

ត្រូវបានទទួលស្គាល់ជា **ភ្នាក់ងារសេវាកម្មពន្ធដារ** ដែលមានអាជ្ញាបណ្ណលេខ TA202003004
តាមប្រកាសលេខ ២៣០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២
មានសុពលភាពចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ដល់ថ្ងៃទី**២៥ ខែមីនា ឆ្នាំ២០២៨**

## TAX AGENT LICENSE

**GENERAL DEPARTMENT OF TAXATION Certifies that**

**T.K BUSINESS CONSULTING CO., LTD.**

is acknowledged as **TAX AGENT** with number TAXID : **TA202003004**
in accordance with Prakas No. 230 MEF.PK dated 23 March, 2022
This License is valid from 25 Mar 2026 to 25 Mar 2028

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦
Phnom Penh, 17 Mar 2026

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

Minister Attached to the Prime Minister
Delegate of the Royal Government
in charge as Director General of General Department of Taxation

**គង់ វិបុល**

កម្រៃសេវាភ្នាក់ងារពន្ធដារ
២,០០០,០០០ រៀល
លេខ SN : EABA2601280902869246

កាលបរិច្ឆេទចេញអាជ្ញាបណ្ណលើកដំបូង ថ្ងៃទី២ ខែមេសា ឆ្នាំ២០២០
First issued date 02 April 2020